កាចាស់

បើលើកពីរុក្ខជាតិអំបូរវល្ជ៍ផ្តៅល្ពាក់ដុះក្នុងធម្មជាតិ ឃើញថាមានច្រើនប្រភេទណាស់ ដែលគេអាចយកមកធ្វើជាឧបករណ៍ប្រើប្រាស់នានាក្នុងជីវិតប្រចាំថ្ងៃដ៏សំបូរបែប ដូចជា កន្ត្រក សង្រែក ខ្សែចំណង។ល។ នេះគួរប្រមូលចងក្រងជាប្រធានបទសិក្សាមួយដ៏មានប្រយោជន៍ អំពីការងារសិប្បកម្មផ្នែកវប្បធម៌ប្រពៃណី បរិស្ថាន និងការអភិរក្សផ្ទេរចំណេះទាំងនេះ។ ខាងក្រោមនេះខ្ញុំបង្ហាញពីករណីសិក្សាមួយអំពី ការផលិត និងការប្រើប្រាស់ ឧបករណ៍ប្រពៃណីមួយប្រភេទរបស់ជនជាតិកួយ ក្នុងភូមិវាលវែង ឃុំឈូក ស្រុកប្រាសាទសំបូរ ក្នុងខេត្តកំពង់ធំ។ ឧបករណ៍ដែលខ្ញុំនឹងលើកយកមកបង្ហាញនេះកួយហៅថា កាចាស់។

កាចាស់ គឺជាឧបករណ៍ប្រើប្រាស់ជាប្រចាំរបស់ជនជាតិកួយ ព្រោះវាអាចដាក់វត្ថុបានច្រើនចម្រុះក្នុងនោះ និងប្រើចាំបាច់សម្រាប់ដាក់របស់ហូបចុកតាមផ្ទូវដូចជា កញ្ចប់បាយ ម្ហូប ដបទឹក នំ ផ្លែឈើ កាំបិត ថ្នាំជក់ស្វាម្ទូ ពេលចេញទៅស្រែចំការ ឬទៅឃ្វាលគោក្របីឆ្ងាយពីផ្ទះ រហូតដល់ល្ងាចទើបត្រឡប់មកផ្ទះវិញ។ ជាញឹកញាប់គេក៏ប្រើកាចាស់ ពេលទៅចាប់ត្រី ទៅបេះបន្លែក្នុងចំការឬក្នុងព្រៃ ដកផ្សិត រើសជ័រចុង បោចវល្ជ៍ កាប់ថ្នាំឈើ រើសគ្រាប់ស្វាយចន្ទី។ល។ ដែលសុទ្ធសឹងអាចដាក់ក្នុងកាចាស់បាន ស្ពាយត្រលប់មកផ្ទះវិញ (រូបលេខ១-៦)។

(រូបលេខ១ៈ ស្ពាយកាចាស់ទៅឃ្វាលក្របី)

(រូបលេខ២ៈ ដាក់ដំឡូងទៀនជីកពីព្រៃ)

(រូបលេខ៣ៈ ស្ពាយកាចាស់ទៅកាប់រំចេក យកមកត្បាញកន្ទេល)

(រូបលេខ៤ៈ ដបទឹកនិងរបស់ផ្សេងៗទៀត)

(រូបលេខ៥ៈដាក់ត្រីអន្ទង់កង្កែបបានពីលើទ្រូ)

(រូបលេខ៦ៈ កង្វាលដាក់កញ្ចប់បាយ ផ្ងែចេក ជំពាមកៅស៊ូ)

រុក្ខជាតិដែលគេយកមកធ្វើកាចាស់ គឺជាពពួកអំបូរផ្តៅម្យ៉ាងមានបន្ទា ស្គាល់ឈ្មោះជាទូទៅថា ឆ្នូរ ឬជាភាសាកួយហៅថា ឫិនៗ ដើមនេះច្រើនដុះនៅតាមព្រៃរបោះមានម្ចប់ជុំដោយដើមឈើឯទៀតតូចធំ និងលូតលាស់ល្អត្រង់ដីសើមក្បែរៗប្រភពទឹកមានអូរជាដើមៗ

អត្ថបទដោយៈ អាន រស្មី

សព្វថ្ងៃអ្នកត្បាញអាចទៅរកបោចឆ្នូរនៅតាមដុបព្រៃក្បែរៗភូមិ ឬក្នុងព្រៃសហគមន៍ដែលគេអភិរក្សទុកជាសម្បត្តិរួម ត្បិតព្រៃក្បែរភូមិស្ថានបានប្រែជាដីចំការស្វាយចន្ទី។ ដោយសារដើមនេះមានបន្ទាច្រូងច្រាងពីគល់ដល់ចុង ដូច្នេះអ្នកបោចត្រូវប្រើផ្តាក់ ឬកាំបិតបន្ទោះមានដងវែងកាន់ ដើម្បីកាប់ និងស្ទួសបកសម្បកបន្ទានោះចេញពីដើមកុំឱ្យមុតដៃ (រូបលេខ៧-៨)។ ដើមដែលគេកាប់មានប្រវែង៣ម៉ែត្រឬ៤ម៉ែត្រឬអាចវែងជាងនេះទៅតាមអាយុរបស់វា។

(រូបលេខ៧ៈ ដើមថ្ងិន)

(រូបលេខ៨ៈ ដើមថ្ងិនដែលគេប្រើកាំបិតបន្ទោះស្ទួសសម្បកបន្ទាចេញអស់)

<u>របៀបធ្វើកាចាស់</u>ៈ គេត្រូវកោសផ្នែកខាងក្រៅសម្បកថ្ងិនឱ្យជ្រះអស់ បន្ទាប់មកពុះវាជាបន្ទោះ៤ទៅ៦ចម្រៀកតាមទំហំដើមតូចឬធំ រួចប្រើកាំបិតបន្ទោះបិតវាជាបន្ទោះស្តើងៗ ដោយស្ទួសយកសាច់ជាប់សម្បកឱ្យអស់ ទុកតែសម្បកសុទ្ធសាទ្ធដែលរឹងសម្រាប់ប្រើការ (រូបលេខ៩)។ ជាដំបូងអ្នកត្បាញចាប់ក្រងបាតវាឱ្យចេញជារូបរាងប្រទាក់ក្រលាគ្នា (រូបលេខ១០)។ នៅផ្ទៃបាតគេទ្រាប់ដោយប៉ដឹសឬស្សីខ្វែងគ្នា ដើម្បីឱ្យវត្ថុនេះមានលំនឹងពេលដាក់បញ្ឈរ (រូបលេខ១១)។ បន្ទាប់មកត្បាញឡើងមកខាងលើជាតួខ្ជួន រហូតដល់ត្រង់មាត់(រូបលេខ១២-១៣)។ ខ្ជួនវាមានសណ្ឋានប៉ោងធំ ហើយរួមបន្តិចត្រង់កក្អេងនិងមាត់។ នៅត្រង់មាត់គេធ្វើកណ្តាប់ពីផ្តៅតាមទំហំមាត់ដែលគេចង់បាន ហើយភ្ជាប់មកខ្ជួន។ មុននឹងក្រងកណ្តាប់ភ្ជាប់មកខ្ជួន គេត្រូវយកខ្ជួនវាទៅត្រាំទឹកមួយសន្ទុះសិន ដើម្បីឱ្យបន្ទោះថ្ងិនច្រូងច្រាងខាងលើទន់ពត់បត់បែនមិនបាក់ និងងាយស្រួលស៊ិកកណ្តាប់ផ្តៅជាមាត់ចូលទៅភ្ជាប់ខ្ជួន (រូបលេខ១៤-១៥)។ បន្ទាប់មកគេត្បាញភ្ជាប់ខ្ជួននឹងកណ្តាប់មាត់ជាចុងក្រោយ (រូបលេខ១៦-១៧)។ កាចាស់

នេះប្រើបានទាល់តែមានខ្សែស្ពាយសម្រាប់កាន់យូរ ឬស្ពាយពាក់នឹងស្មា។ ខ្សែនេះទៀត សោតគេវេញពីបន្ទោះថ្ងិនដូចគ្នា។

(រូបលេខ៩ៈ អ្នកត្បាញប្រើកាំបិតបន្ទោះស្ទូសសម្បកថ្ងិន និងបិតជាបន្ទោះតូចៗសម្រាប់ក្រង)

(រូបលេខ១០)

(រូបលេខ១១)

(រូបលេខ១២)

(រូបលេខ១៣)

អត្ថបទដោយៈ អាន រស្មី

(រូបលេខ១៤)

(រូបលេខ១៥)

(រូបលេខ១៦)

(រូបលេខ១៧)

ទម្លាប់ប្រើកាចាស់ជាទំនៀមមួយយូរយារមក ហើយក្លាយជាអត្តសញ្ញាណសម្គាល់ជនជាតិកួយ។ សព្វថ្ងៃអ្នកដែលចេះធ្វើកាចាស់ មានមិនច្រើនទេក្នុងភូមិ ឯអ្នកចេះទៀតសោតច្រើនជាមនុស្សចាស់នៅរក្សាផ្ទះ។ មួយវិញទៀត បរិស្ថាននៅជុំវិញភូមិស្ថានដែលអាចឱ្យដើមថ្ងិនដុះលូតលាស់បាន ចេះតែប្រែប្រួលដោយការឈូសឆាយដីប្រើប្រាស់ទៅជាចំការស្វាយចន្ទី ដូច្នេះទៅដើមថ្ងិនចេះតែហោចទៅៗរួមមកនៅតាមដុបព្រៃតូចៗជាប់ចំការ និងក្នុងព្រៃសហគមន៍ដែលគេអភិរក្សទុក។ ដូច្នេះការរក្សាបរិស្ថាន និងការសិក្សាចងក្រង ផ្សព្វផ្សាយ ផ្ទេរចំណេះ មានសារៈសំខាន់ណាស់ ក្នុងការអភិរក្ស និងលើកតម្លៃសិប្បកម្មប្រពៃណីមួយនេះ។

អត្ថបទដោយ៖ អាន រស្មី